**តើកម្មវិធីសុខភាពផ្លូវចិត្ត Field Capable Clinical Services (FCCS) និង Full Service Partnership (FSP) ជាកម្មវិធីអ្វីទៅ?**

**FCCS និង FSP**
បង្កើតឡើងសំរាប់ផ្តល់នូវសេវាខាងសុខភាពផ្លូវចិត្ត សំរាប់មនុស្សព្រឹទ្ធវ័យ ដែលមានអាយុពី 55ឆ្នាំឡើងទៅ ដែលមានការលំបាកក្នុងការធ្វើដំណើរចេញក្រៅផ្ទះ ដោយហេតុមានភាពជរា មានជំងឺ និងការលំបាកផ្សេងៗទៀត ដែលត្រូវការជាចាំបាច់ នូវជំនួយផ្លូវចិត្ត សុខភាពផ្លូវកាយ និងការរស់នៅជាទូទៅ។

បុគ្គលិកយើងផ្តល់សេវាទាំងអស់ នៅកន្លែងណា-មួយ ដែលងាយស្រួលសំរាប់លោកអ្នក ដូចជានៅផ្ទះលោកអ្នកផ្ទាល់ ក្នុងសហគមន៍លោកអ្នក ឬកន្លែងផ្សេងៗណាមួយ ដែលងាយស្រួលសំរាប់លោកអ្នក។




**សេវាកម្ម FCCS និង FSP**

មានបុគ្គលិកខ្មែរ
ពិគ្រោះយោបល់
ជួយខាងថ្នាំពេទ្យ
បង្ហាត់បង្រៀន និងជួយណែនាំទៅកម្មវិធីផ្សេងៗ
ជួយខាងការប្រាស្រ័យទាក់ទងគ្នា ក្នុងសហគមន៍លោកអ្នក
ជួយខាងរៀបចំការរស់នៅ
ជួយខាងការស្វែងរកជំនួយខាងលុយកាក់ និងខាងសុខភាព ដែលលោកអ្នកអាចទទួលបាន

សំរាប់លោកអ្នកនៅក្នុងកម្មវិធី **FSP** លោកអ្នកទទួលជំនួយបាន 24ម៉ោងក្នុងមួយថ្ងៃ និង7ថ្ងៃក្នុងមួយអាទិត្យ។



លោកអ្នកដែលអាចចូលរួមក្នុងកម្មវិធីបាន

**FCCS**

លោកអ្នកដែលមានអាយុពី 55ឆ្នាំឡើងទៅ ដែល-មានការលំបាកក្នុងការរស់នៅសព្វថ្ងៃនេះ ដោយ-សារមានការលំបាកខាងផ្លូវចិត្ត ការព្រួយចិត្ត ភាពបារម្ភ ឬមានការភ័យខ្លាចពីអ្វីមួយ ។

**FSP**

លោកអ្នកដែលមានអាយុពី 60ឆ្នាំឡើងទៅ ដែលមានការលំបាកធ្ងន់ធ្ងរក្នុងការរស់នៅ ដោយសាមានបញ្ហាសុខភាពផ្លូវចិត្តយ៉ាងខ្លាំង ធ្លាប់មានបញ្ហាអត់ផ្ទះនៅ ធ្លាប់ចូលសំរាកនៅមន្ទីរពេទ្យផ្នែកសុខភាពផ្លូវចិត្តជាញឹកញាប់ ឬលោកអ្នកដែលអាចនឹងមានបញ្ហាដូចរៀបរាប់ខាងលើនេះ។

